**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** អនុក្រឹត្យនេះមានគោលដៅផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិកម្ពុជា ។

**មាត្រា២ :** ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមទៅលើប្រាក់បៀវត្សរ៍មូលដ្ឋានប្រចាំខែ ហើយត្រូវបានបែងចែកជា ០៥ កម្រិតទៅតាមរយៈពេល និងបទពិសោធន៍ការងារក្នុងមុខតំណែងនីមួយៗដូចខាងក្រោម :

- កម្រិតទី៥ សម្រាប់បទពិសោធន៍ រយៈពេលក្រោម ៣ ឆ្នាំ
- កម្រិតទី៤ សម្រាប់បទពិសោធន៍ រយៈពេល ៣ ឆ្នាំ ទៅ ៦ឆ្នាំ
- កម្រិតទី៣ សម្រាប់បទពិសោធន៍ រយៈពេល ៦ ឆ្នាំ ទៅ ១០ឆ្នាំ
- កម្រិតទី២ សម្រាប់បទពិសោធន៍ រយៈពេល ១០ ឆ្នាំ ទៅ ១៦ឆ្នាំ
- កម្រិតទី១ សម្រាប់បទពិសោធន៍ រយៈពេលលើសពី ១៦ ឆ្នាំ

**មាត្រា៣** : មន្ត្រីនគរបាលជាតិកម្ពុជាដែលកំពុងបំពេញមុខងារនៅក្នុងមុខតំណែងដូចមានកំណត់នៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែដូចមានកំណត់ក្នុងតារាងខាងក្រោម :

| ល.រ | មុខតំណែងជាមូលដ្ឋាន | កម្រិតទី៥ | កម្រិតទី៤ | កម្រិតទី៣ | កម្រិតទី២ | កម្រិតទី១ |
|---|---|---|---|---|---|---|
| ១ | អគ្គស្នងការ | ១.៥៥០.០០០៛ | ១,៦០០,០០០៛ | ១.៦៥០,០០០៛ | ១.៧០០.០០០៛ | ១.៧៥០,០០០៛ |
| ២ | អគ្គស្នងការរង | ៧៥០.០០០៛ | ៧៩៥.០០០៛ | ៨៤៣,០០០៛ | ៨៩៤.០០០៛ | ៩៤៧.០០០៛ |
| ៣ | ប្រធាននាយកដ្ឋាន | ៦២០.០០០៛ | ៦៥៨.០០០៛ | ៦៩៨.០០០៛ | ៧៤១,០០០៛ | ៧៨៦.០០០៛ |
| ៤ | អនុប្រធាននាយកដ្ឋាន | ៥៣០,០០០៛ | ៥៧០.០០០៛ | ៦១០,០០០៛ | ៦៥០,០០០៛ | ៦៩០,០០០៛ |
| ៥ | នាយការិយាល័យចំណុះនាយកដ្ឋាន | ៤៣០,០០០៛ | ៤៥០.០០០៛ | ៤៧០.០០០៛ | ៤៩០,០០០៛ | ៥១០,០០០៛ |
| ៦ | នាយរងការិយាល័យចំណុះនាយកដ្ឋាន | ៣៨០,០០០៛ | ៤០០.០០០៛ | ៤២០,០០០៛ | ៤៤០,០០០៛ | ៤៦០.០០០៛ |
| ៧ | នាយផ្នែកចំណុះនាយកដ្ឋាន | ៣១០,០០០៛ | ៣៣០.០០០៛ | ៣៥០.០០០៛ | ៣៧០.០០០៛ | ៣៩០.០០០៛ |
| ៨ | នាយរងផ្នែកចំណុះនាយកដ្ឋាន | ២៦០,០០០៛ | ២៨០.០០០៛ | ៣០០,០០០៛ | ៣២០,០០០៛ | ៣៤០.០០០៛ |
| ៩ | នាយផ្នែកចំណុះអធិការដ្ឋាន | ២០០.០០០៛ | ២២០.០០០៛ | ២៤០,០០០៛ | ២៦០.០០០៛ | ២៨០,០០០៛ |
| ១០ | នាយប៉ុស្តិ៍នគរបាលរដ្ឋបាល | ១៥០,០០០៛ | ១៦៥.០០០៛ | ១៨០,០០០៛ | ១៩៥.០០០៛ | ២១០.០០០៛ |
| ១១ | នាយរងផ្នែកចំណុះអធិការដ្ឋាន | ១២០.០០០៛ | ១៣៥.០០០៛ | ១៥០,០០០៛ | ១៦៥.០០០៛ | ១៨០,០០០៛ |
| ១២ | នាយក្រុមតម្រួតបទបញ្ជា ខេត្ត-ក្រុង | ៩០,០០០៛ | ១០០,០០០៛ | ១១០,០០០៛ | ១២០.០០០៛ | ១៣០,០០០៛ |
| ១៣ | នាយរងក្រុមតម្រួតបទបញ្ជា ខេត្ត-ក្រុង | ៦០,០០០៛ | ៦៥.០០០៛ | ៧០,០០០៛ | ៧៥,០០០៛ | ៨០,០០០៛ |
| ១៤ | នាយក្រុមនគរបាលការពារ | ៤៦,០០០៛ | ៤៧,០០០៛ | ៤៨,០០០៛ | ៤៩,០០០៛ | ៥០,០០០៛ |
| ១៥ | នាយរងក្រុមនគរបាលការពារ | ៤៤,០០០៛ | ៤៥,០០០៛ | ៤៦,០០០៛ | ៤៧,០០០៛ | ៤៨,០០០៛ |
| ១៦ | មន្ត្រីនគរបាលជាតិ | ៤១,០០០៛ | ៤២,០០០៛ | ៤៣,០០០៛ | ៤៤,០០០៛ | ៤៥,០០០៛ |

**មាត្រា៤** : មុខតំណែងដទៃទៀត ដែលស្មើមុខតំណែងជាមូលដ្ឋានខាងលើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៥** : មន្ត្រីនគរបាលជាតិកម្ពុជាដែលស្ថិតនៅក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងនោះ ករណីមន្ត្រីនគរបាលដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតឱ្យជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយគត់ ។

**មាត្រា៦** : មន្ត្រីនគរបាលជាតិដែលមានសិទ្ធិទទួលប្រាក់បំណាច់មុខងារ ត្រូវស្ថិតក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម :

១- កំពុងបំពេញការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

២- កំពុងផ្លាស់ប្ដូរកន្លែងធ្វើការ និងកំពុងធ្វើដំណើរទៅកាន់មុខតំណែង នៅក្នុងឬ ក្រៅប្រទេស

៣- កំពុងបំពេញការសិក្សាក្នុង និងក្រៅប្រទេសតាមតម្រូវការរបស់នគរបាលជាតិ

៤- មន្ត្រីនគរបាលជាតិ ពលី ពិការ មរណៈ ចូលនិវត្តន៍ និងចូលបាត់បង់សមត្ថភាពការងារដែលមិនទាន់កាត់ផ្ដាច់ក្របខ័ណ្ឌចេញពីក្រសួងមហាផ្ទៃ

៥- មន្ត្រីនគរបាលជាតិដែលបានអនុញ្ញាតច្បាប់ក្នុងចុះផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម "

**មាត្រា ៧** : ការបញ្ឈប់ផ្តល់ប្រាក់បំណាច់មុខងារ ត្រូវធ្វើទៅតាមថ្ងៃខែកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងករណីខាងក្រោមនេះ :

១- មន្ត្រីនគរបាលជាតិដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត

២- មន្ត្រីនគរបាលជាតិដែលមានប្រកាសបណ្តេញចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

៣- មន្ត្រីនគរបាលជាតិដែលអវត្តមានគ្មានការអនុញ្ញាត ឬ ហួសកំណត់ដោយប្រធានសក្តិមិនសមស្រប

៤- មន្ត្រីនគរបាលជាតិ ពលី ពិការ ចូលនិវត្តន៍ និងចូលបាត់បង់សមត្ថភាពការងារដែលបានកាត់ផ្តាច់ក្រប-ខ័ណ្ឌចេញពីក្រសួងមហាផ្ទៃ

៥- មន្ត្រីនគរបាលជាតិដែលមានសាលក្រមតុលាការបញ្ជាក់ថាជាទណ្ឌិត ។

**មាត្រា ៨** : ប្រាក់របបផ្សេងៗទៀត ក្រៅពីប្រាក់បំណាច់មុខងារ ត្រូវបន្តអនុវត្តជាធរមាន ។

**មាត្រា ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

***កន្លែងទទួល*** :

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*ដូចមាត្រា ៩*
*រាជកិច្ច*
*កាលប្បវត្តិ-ឯកសារ*